# ឱកាស!ចូលរួមវគ្គបណ្ដុះបណ្ដាលកសាងសមត្ថភាពផ្នែកតូរ្យតន្ត្រី

សិល្បៈខ្មែរអមតៈ សហការជាមួយសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (មហាវិទ្យាល័យតូរ្យតន្ត្រី) និងសាលាតូរ្យតន្ត្រី ហ៊ឹម សុភី មានសេចក្ដីរីករាយនឹងប្រកាសបើក វគ្គបណ្ដុះបណ្ដាលផ្នែកតូរ្យតន្ត្រីរយៈពេល ៤ សប្ដាហ៍ ក្នុងគោលបំណង កសាងសមត្ថភាពសិល្បករជំនាន់ក្រោយ តាមរយៈការហាត់សមស្នាដៃបទភ្លេងនិពន្ធថ្មី (ស្នាដៃបង្សុកូល) ។

សិល្បៈខ្មែរអមតៈ

HIM SOPHY SCHOOL OF MUSIC

ក្នុងវគ្គបណ្ដុះបណ្ដាលនេះ យើងត្រូវការជ្រើសរើស សិល្បករសិស្សសិល្បៈចំនួន៨នាក់សម្រាប់ឯកទេសដូចខាងក្រោម៖

- អ្នកចម្រៀងប្រុសសម្លេងខ្ពស់ (Tenor) ១នាក់
- អ្នកចម្រៀងស្រីសម្លេងខ្ពស់ (Soprano) ១នាក់
- គងភ្លោះ ១នាក់
- រនាតភ្លោះ ១នាក់
- ទ្រ ១នាក់
- ឧបករណ៍ផ្លុំ (ស្រឡៃ ខ្លុយ ប៉ី) និងស្គរសំភោរ ១នាក់
- ពិណ ២នាក់

កាលបរិច្ឆេទហាត់សម៖ រយៈពេល៤សប្ដាហ៍ ប្រព្រឹត្តទៅជារៀងរាល់ព្រឹក ពីម៉ោង ៨ព្រឹកដល់១២ថ្ងៃត្រង់ នៅសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ។

- សប្ដាហ៍ទី ១: ថ្ងៃទី២៨ ខែសីហា ដល់ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៧
- សប្ដាហ៍ទី ២: ថ្ងៃទី១-៤ ខែកញ្ញា ឆ្នាំ២០១៧
- សប្ដាហ៍ទី ៣: ថ្ងៃទី១១-១៥ ខែកញ្ញា ឆ្នាំ២០១៧
- សម្រាកភ្ជុំបិណ្ឌ ថ្ងៃទី១៨-២២ ខែកញ្ញា ឆ្នាំ២០១៧
- សប្ដាហ៍ទី ៤: ថ្ងៃទី២៥-២៩ ខែកញ្ញា ឆ្នាំ២០១៧

លក្ខខណ្ឌជ្រើសរើស៖

- អាចអានអក្សរភ្លេងបាន
- កំពុងរស់នៅទីក្រុងភ្នំពេញ
- មានការប្ដេជ្ញាចិត្តខ្ពស់ និងពេលវេលាគ្រប់គ្រាន់សម្រាប់ការហាត់សមឲ្យបានទៀងទាត់តាមកាលវិភាគដែលបានកំណត់។

ទម្រង់នៃការស្នើសុំ៖

- ត្រូវតែជាពាក្យស្នើសុំ ដែលអាចទាញយកបានតាមរយៈគេហទំព័រសិល្បៈខ្មែរអមតៈ ឬមកយកផ្ទាល់នៅការិយាល័យសិល្បៈខ្មែរអមតៈ នៅមហាវិទ្យាល័យតូរ្យតន្ត្រីនៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ឬនៅសាលាតូរ្យតន្ត្រីហ៊ឹម សុភី ។
- ពាក្យស្នើសុំអាចបំពេញដោយដៃ ឬដោយកុំព្យូទ័រ ។ ប្រសិនបើបេក្ខជនមានការលំបាកក្នុងការបំពេញពាក្យស្នើសុំ អាចទាក់ទងមកលេខទូរស័ព្ទ ០១០ ៩៤១ ២២៤ សម្រាប់ព័ត៏មានបន្ថែម។

ដំណើរការនៃការជ្រើសរើស៖

- ការធ្វើតេស្តសមត្ថភាពនឹងត្រូវធ្វើឡើងនៅចន្លោះថ្ងៃទី ២២ - ២៥ ខែសីហា ឆ្នាំ២០១៧ នៅសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ។ បេក្ខជនដែលដាក់ពាក្យស្នើសុំ នឹងត្រូវបានទាក់ទងដោយអង្គការសិល្បៈខ្មែរអមតៈ ។
- គណៈកម្មការមានសមាជិក ៥ នាក់ ដែលជាតំណាងមកពីអង្គការសិល្បៈខ្មែរអមតៈ និងដៃគូសហការ ដូចជាមហាវិទ្យាល័យតូរ្យតន្ត្រី, សាលាតូរ្យតន្ត្រី ហ៊ឹម សុភី និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ។

អ្នកចូលរួម នឹងទទួលបានប្រាក់ឧបត្ថម្ភ ៧ ដុល្លា/នាក់ សម្រាប់ ១ ថ្ងៃ ព្រមទាំងឱកាសចូលរួមទស្សនាការហាត់សមស្នាដៃ "បង្សុកូល" ក្នុងខែតុលា ឆ្នាំ២០១៧ ខាងមុខនេះ។

សូមផ្ញើពាក្យស្នើសុំមកកាន់អ៊ីម៉ែល sormanak@cambodianlivingarts.org ឬមកដាក់ដោយផ្ទាល់នៅអង្គការសិល្បៈខ្មែរអមតៈដែលមានអាសយដ្ឋានផ្ទះលេខ ១២៨G៩ ផ្លូវសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ, លេខទូរស័ព្ទ ០១០ ៩៤១ ២២៤